ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ០៣៧ សជល.សក.មសស

ថ្ងៃ ១៨កើត ១៤រោចខែមាឃ ឆ្នាំរកា នព្វស័ក ពស ២៥៦១

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្តល់អាហារូបករណ៍ថ្នាក់អនុបណ្ឌិតឆ្នាំ២០១៨
## នៅសាកលវិទ្យាល័យ North China Electric Power University

អគ្គិសនីកម្ពុជា សូមជម្រាបដល់និយោជិតអគ្គិសនីកម្ពុជាទាំងអស់ឲ្យបានជ្រាបថាក្នុងឆ្នាំ២០១៨ ក្រុមហ៊ុនCHMC ដែលជាដៃគូអភិវឌ្ឍន៍ជាមួយអគ្គិសនីកម្ពុជា បានផ្តល់អាហារូបករណ៍សិក្សាថ្នាក់អនុបណ្ឌិតដល់ និយោជិតអគ្គិសនីកម្ពុជា សម្រាប់ការអភិវឌ្ឍន៍ ទេពកោសល្យជំនាញនៅសាកលវិទ្យាល័យ North China Electric Power University នៅទីក្រុងប៉េងកាំង ប្រទេសចិន ហើយរាល់ការចំណាយទាំងអស់គឺជាបន្ទុករបស់ក្រុមហ៊ុន។ អាហារូបករណ៍ថ្នាក់អនុបណ្ឌិត នេះផ្តល់ជូនទៅលើប្រភេទ ឯកទេស និងតម្រូវការលក្ខខណ្ឌដូចខាងក្រោម៖

I-<u>ប្រភេទឯកទេស:</u>

ថ្នាក់អនុបណ្ឌិត (Master's Degree)ជំនាញអគ្គិសនីលើមុខវិទ្យា Master Degree in Thermal Power Engineering (Specific on Coal Power Plant) សិក្សារយៈពេលចាប់ពី០២ឆ្នាំនិង០៥ខែរហូតដល់០៣ឆ្នាំ ចំនួន:០២កន្លែង។

II- <u>លក្ខខណ្ឌនៃការជ្រើសរើស:</u>

ចំពោះនិយោជិតដែលត្រូវបានជ្រើសរើសដើម្បីទទួលបានអាហារូបករណ៍នេះត្រូវមាន លក្ខណៈសម្បត្តិដូចខាងក្រោម:

- ត្រូវមានសញ្ញាបត្រវិស្វករអគ្គិសនី/វិស្វករសំណង់/វិស្វករមេកានិច (ភ្ជាប់មកជាមួយនូវព្រឹត្តិបត្រពិន្ទុ)
- ត្រូវមានអតីតភាពការងារនៅអគ្គិសនីកម្ពុជាយ៉ាងតិចចំនួន០១ឆ្នាំ
- ត្រូវមានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស
- ត្រូវមានប្រវត្តិការងារល្អចេះធ្វើការជាក្រុមមានស្មារតីគោរពវិន័យតាមការចាត់តាំងរបស់អង្គភាព ជាអ្នកមាន សក្តានុពល ទាំងផ្នែកបច្ចេកទេសនិងផ្នែកដឹកនាំ សម្រាប់ទៅថ្ងៃអនាគត។
- ត្រូវមានអាយុក្រោម៣៥ឆ្នាំ គិតត្រឹមថ្ងៃឈប់ទទួលពាក្យ

III-<u>ពាក្យស្នើសុំ និងទីកន្លែងទទួលពាក្យ:</u>

និយោជិតអគ្គិសនីកម្ពុជាដែលមានបំណងចង់ដាក់ពាក្យស្នើសុំអាហារូបករណ៍ ថ្នាក់អនុបណ្ឌិត អាចចូលទៅកាន់ www.edc.com.kh/scholarship ដើម្បីទទួលពាក្យស្នើសុំ និងបញ្ជូនមកការិយាល័យមូលនិធិសង្គមនិងអាហារូបករណ៍ឲ្យបាន មុនថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។

អាស្រ័យហេតុនេះ សូមនិយោជិតអគ្គិសនីកម្ពុជាដែលមានបំណងចង់បន្តការសិក្សាថ្នាក់អនុបណ្ឌិតនេះ និងមាន លក្ខណៈសម្បត្តិសមស្របសូមចូលរួមដាក់ពាក្យជាបេក្ខភាពតាមការគួរ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

<u>ចម្លងជូន:</u>

-អគ្គនាយករង អគ្គិសនីកម្ពុជា

ដើម្បី "<u>ជ្រាបជាព័ត៌មាន</u>"

-ប័ណ្ណសារ - កាលប្បវត្តិ

អគ្គិសនីកម្ពុជា : # ២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : ០២៣ ៧២៣ ៩៧១ - ៧២៤ ៧៧១ ទូរសារ : (៨៥៥) ២៣ ៤២៦ ០១៨